ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៥៥៧......សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការទទួលស្គាល់ និងការតព្វកិច្ចពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្ដីពីពន្ធលើប្រាក់ចំណេញ
- យោងតាមតម្រូវការចាំបាច់នៃការគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកំណត់វិធាន និងនីតិវិធីនៃការទទួលស្គាល់ និងការបំពេញកាតព្វកិច្ចពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ស្របតាមមាត្រា៥២ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌនៃការផ្គត់ផ្គត់ផ្គង់ទំនិញឬសេវារបស់ភ្នាក់ងារក្នុងនាមសហគ្រាសដើម។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមសហគ្រាសដើមជាអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- លក្ខខណ្ឌដើម្បីទទួលបានលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម**

អនុលោមតាមមាត្រា៥២ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមការផ្គត់ផ្គង់ទំនិញឬសេវាធ្វើឡើងដោយបុគ្គលជាភ្នាក់ងារ ដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាសហគ្រាសដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់សហគ្រាសដើមនោះ។ ដើម្បីទទួលបានលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

ក. ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ត្រូវតែជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

ខ. ត្រូវមានកិច្ចសន្យារវាងសហគ្រាសដើមនិងភ្នាក់ងារ និងឯកសារគាំទ្រផ្សេងៗដែលបញ្ជាក់អំពីទំនាក់ទំនងគ្នារវាងសហគ្រាសដើមនិងភ្នាក់ងារ។

គ. សហគ្រាសដើម ត្រូវកំណត់តម្លៃទំនិញឬសេវា ព្រមទាំងកម្រៃជើងសា ឱ្យភ្នាក់ងារ។

ឃ. សន្និធិទំនិញ នៅតែជាកម្មសិទ្ធិរបស់សហគ្រាសដើម នៅពេលដែលទំនិញមិនទាន់ត្រូវបានផ្គត់ផ្គង់។

ង. នៅពេលផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន ភ្នាក់ងារអាចប្រើប្រាស់វិក្កយបត្ររបស់ខ្លួន ដោយរំលេចឈ្មោះរបស់សហគ្រាសដើម ឬប្រើប្រាស់វិក្កយបត្ររបស់សហគ្រាសដើម។ សហគ្រាសដើម និងភ្នាក់ងារត្រូវជ្រើសរើសការប្រើប្រាស់វិក្កយបត្រណាមួយក្នុងចំណោមវិក្កយបត្រទាំងពីរប្រភេទ ហើយប្រើប្រាស់ពេញមួយឆ្នាំជាប់ពន្ធ។ វិក្កយបត្រត្រូវមានលំដាប់លេខរៀងដោយឡែកសម្រាប់សហគ្រាសដើមនីមួយៗ។

ច. ភ្នាក់ងារត្រូវចេញវិក្កយបត្រអាករ លើកម្រៃជើងសាពីការផ្គត់ផ្គង់ទំនិញឬសេវាឱ្យសហគ្រាសដើម។ សហគ្រាសដើម ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលនូវអាករលើតម្លៃបន្ថែមដែលបានបង់ទៅឱ្យភ្នាក់ងារ។

ឆ. ភ្នាក់ងារត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែនូវតារាងលម្អិតអំពីការផ្គត់ផ្គង់ទំនិញ ឬសេវា (ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ) ហើយត្រូវរាយការណ៍អំពីចលនាសន្និធិជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ត្រីមាស យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ក្រោយដំណាច់ត្រីមាសនីមួយៗ។

**ប្រការ ៥.- ការស្នើសុំទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមសហគ្រាសដើម**

១. សហគ្រាសដូចមានចែងក្នុងប្រការ៤ ខាងលើ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម មកអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

ក. កិច្ចសន្យាភ្នាក់ងារទទួលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

ខ. ឯកសារចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

គ. គំរូវិក្កយបត្រដូចមានចែងក្នុងកថាខណ្ឌ ង នៃប្រការ ៤ នៃប្រកាសនេះ។

២. អគ្គនាយកដ្ឋានពន្ធដារ ត្រូវចេញលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ដែលមានសុពលភាព ០២ (ពីរ) ឆ្នាំ។

៣. ភ្នាក់ងារត្រូវជូនដំណឹងយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ មកអគ្គនាយកដ្ឋានពន្ធដារ ក្រោយពេលមានការផ្លាស់ប្តូរព័ត៌មាន ឬបញ្ឈប់កិច្ចសន្យារវាងភ្នាក់ងារនិងសហគ្រាសដើម។

៤. សហគ្រាសដែលបានទទួលលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម មិនអាចផ្ទេរសិទ្ធិផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ឱ្យបុគ្គលដទៃទៀតឡើយ។

៥. ក្នុងករណីមិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ លិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមនឹងត្រូវអស់សុពលភាពភ្លាម ហើយសហគ្រាសត្រូវអនុវត្តតាមវិធាននៃការផ្គត់ផ្គង់ទំនិញឬសេវាជាធម្មតា។

**ប្រការ ៦.- ការស្នើសុំបន្តសុពលភាពជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម**

១. សហគ្រាសដែលស្នើសុំបន្តសុពលភាពជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនពេលផុតសុពលភាព ទៅតាមទម្រង់ដែលបានកំណត់ និងត្រូវភ្ជាប់មកជាមួយនូវឯកសារនានា ដូចខាងក្រោម÷

ក. ច្បាប់ចម្លងនៃលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

ខ. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម) និងប័ណ្ណពន្ធប៉ាតង់។

គ. កិច្ចសន្យាភ្នាក់ងារទទួលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

២. ក្នុងករណីមិនបានស្នើសុំបន្តសុពលភាពដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ សហគ្រាសលែងត្រូវបានទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ហើយការផ្គត់ផ្គង់ទំនិញឬសេវាត្រូវចាត់ទុកជាប្រតិបត្តិការធម្មតា មិនស្ថិតក្រោមលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមឡើយ។

**ប្រការ ៧.- កម្រៃសេវាលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម**

ភ្នាក់ងារត្រូវបង់កម្រៃសេវាចំនួន ៤០០ ០០០៛ (បួនរយពាន់រៀល) សម្រាប់ការស្នើសុំលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម និង ២០០ ០០០៛ (ពីររយពាន់រៀល) សម្រាប់ការស្នើសុំបន្តសុពលភាព។

**ប្រការ ៨.- ការបំពេញកាតព្វកិច្ចពន្ធអាកររបស់ភ្នាក់ងារ**

១. ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមត្រូវបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។ សម្រាប់គោលដៅនៃការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវមានកាតព្វកិច្ចប្រមូលពន្ធអាករនានាជំនួសមុខឱ្យសហគ្រាសដើម ក៏ប៉ុន្តែពុំមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ជូនរដ្ឋបាលសារពើពន្ធទេ ដោយហេតុថាពន្ធអាករទាំងនេះ ជាកាតព្វកិច្ចរបស់សហគ្រាសដើម។ ពន្ធអាករដែលត្រូវប្រមូលជំនួសមុខឱ្យសហគ្រាសដើមមានដូចខាងក្រោម÷

ក. **អាករពិសេសលើទំនិញនិងសេវាមួយចំនួន÷** ក្នុងករណីដែលទំនិញឬសេវាណាមួយត្រូវជាប់អាករពិសេសលើទំនិញនិងសេវាមួយចំនួន ភ្នាក់ងារត្រូវគិតអាករនេះដោយផ្អែកលើមូលដ្ឋាន និងអត្រា ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីអាករពិសេសលើទំនិញនិងសេវាមួយចំនួន។

ខ. **អាករសម្រាប់បំភ្លឺសាធារណៈ÷** ក្នុងករណីដែលទំនិញណាមួយត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ ភ្នាក់ងារត្រូវគិតអាករនេះដោយផ្អែកលើមូលដ្ឋាន និងអត្រាដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ។

គ. **អាករលើតម្លៃបន្ថែម÷** រាល់ការផ្គត់ផ្គង់ទំនិញឬសេវា ភ្នាក់ងារត្រូវគិតអាករលើតម្លៃបន្ថែមលើមូលដ្ឋានតម្លៃសរុបរួមបញ្ចូលអាករទាំងអស់លើកលែងតែអាករលើតម្លៃបន្ថែមខ្លួនឯង។

២. ចំពោះកម្រៃដែលបានពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវចេញវិក្កយបត្រអាករទៅឱ្យសហគ្រាសដើម ដោយគិតអាករលើតម្លៃបន្ថែម និងធ្វើការប្រកាសបង់អាករនេះ និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធ តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ កម្រៃដែលទទួលបានពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមនេះ មិនមែនជាកម្មវត្ថុនៃអាករសម្រាប់បំភ្លឺសាធារណៈទេ។

**ប្រការ ៩.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ឬអគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ